# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៤ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## រូបសញ្ញារបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ ៤៨អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតរូបសញ្ញារបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់ប្រើក្នុងដំណើរការការងាររបស់ក្រសួង។

រូបសញ្ញារបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២.-**

រូបសញ្ញារបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានរូបភាពជារាងមូល ដោយចែកចេញជា៣តំបន់ (៣ស្រទាប់) និងមានពណ៌ចម្រុះរំលេចលើផ្ទៃនិងអក្សរដូចតទៅ៖

១. តំបន់ទី១ឬស្រទាប់ខាងក្រៅ មានឈ្មោះក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាភាសាខ្មែរនៅផ្នែកខាងលើ និងភាសាអង់គ្លេសនៅផ្នែកខាងក្រោម ខណ្ឌភាសាទាំង២ដោយផ្កាចន្ទន៍ពណ៌លឿង។

២. តំបន់ទី២ឬស្រទាប់កណ្តាល ខណ្ឌដាច់ពីតំបន់ទី១ ដោយរង្វង់ព័ទ្ធពណ៌ស។ ក្នុងតំបន់នេះ ត្រូវបានបែងចែកជា៤ផ្នែកសំខាន់ៗ៖

- និមិត្តរូបនៃការងារវិទ្យាសាស្ត្រដែលមានផ្ទៃពណ៌លឿងទុំ
- និមិត្តរូបនៃការងារបច្ចេកវិទ្យាដែលមានផ្ទៃពណ៌បៃតង
- និមិត្តរូបនៃការងារនវានុវត្តន៍ដែលមានផ្ទៃពណ៌មាស
- និមិត្តរូបនៃការងារទឹកស្អាតដែលមានផ្ទៃពណ៌ផ្ទៃមេឃចាស់។

៣. តំបន់ទី៣ឬផ្ចិតរង្វង់ ជាតំបន់មួយបង្កប់នូវចំណុចសំខាន់ៗ៖

- រូបកងស្ពឺនៃគ្រឿងចក្រមានចំនួន២៥កាំ ជាពណ៌មាសបង្ហាញពីវិស័យឧស្សាហកម្ម គ្របដណ្តប់ និងអភិវឌ្ឍនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- ជើងពានទ្រូវរូបប្រាសាទអង្គរវត្តពណ៌មាស បង្ហាញអំពីផលិតផលដ៏សម្បូណ៌បែបនៅក្នុងវិស័យសិប្បកម្មដែលកើតចេញមកពីគំនិតច្នៃប្រឌិតរបស់ផលិតករខ្មែរ និងជាមូលដ្ឋានគ្រឹះនៃផលិតកម្មក្នុងការទ្រទ្រង់ដល់ខឿនឧស្សាហកម្មកម្ពុជា
- រូបប្រាសាទអង្គរវត្តនៅលើជើងពាន បង្ហាញពីអារ្យធម៌ ល្បីល្បាញ កិត្យានុភាព និងមោទនភាពនៃទឹកដីអង្គរ
- ហត្ថាទាំងទ្វេទ្រជើងពាន បង្ហាញពីស្នាដៃឯកដ៏ល្អ និងភាពប៉ិនប្រសប់ប្រកបដោយទេពកោសល្យរស់រវើករបស់ប្រជាជនកម្ពុជា ដែលមានប្រពៃណីជាយូរលង់មកតាំងពីមុនសម័យអង្គរក្នុងការកសាងអភិវឌ្ឍមាតុភូមិឱ្យសម្បូណ៌រុងរឿង។

៤. តំបន់ទាំង៣ឬស្រទាប់ទាំង៣ មានផ្ទៃនិងអក្សររំលេចដោយពណ៌ខៀវចាស់ ផ្ទៃមេឃចាស់ ពណ៌លឿងទុំ ពណ៌មាស ពណ៌បៃតង ពណ៌ស គឺបង្ហាញអំពីភាពរីកចម្រើន អនាគតរុងរឿង ការជឿនលឿន ការការពារបរិស្ថាន សុខុមាលភាពសង្គម ការផ្តល់នូវគំនិតផ្តួចផ្តើមចម្រុះ និងការធ្វើពិពិធកម្មផលិតកម្មក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ រួមទាំងវិស័យសិប្បកម្ម និងទឹកស្អាត។

**មាត្រា៣ ..**

រូបសញ្ញារបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

- ដាក់លើក្បាលលិខិតផ្លូវការរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ប្រើប្រាស់ក្នុងករណីចាំបាច់ផ្សេងៗដែលកំណត់ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**មាត្រា៤ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥** ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤ រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា**

**និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០២០

រូបសញ្ញារបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍